ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងព្រហ្មទណ្ឌលេខៈ ១៩៨៩ អ.ក
ចុះថ្ងៃទី២៩-វិច្ឆិកា-២០២១
សាលក្រមលេខៈ ៨៦ (ឱ)
ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២

## តាមនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តកណ្តាល

-បានបើកសវនាការជាអសាធារណៈ នៅសាលសវនាការ នៃសាលាដំបូងខេត្តកណ្តាល នាថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ វេលាម៉ោង០៩ព្រឹក ដោយមានសមាសភាពដូចតទៅ÷

**ក្រុមប្រឹក្សាជំនុំជម្រះ**

-លោក [redacted] ជាប្រធានក្រុមប្រឹក្សា
-លោក ជាចៅក្រមប្រឹក្សា
-លោក ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

-លោកស្រី [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកណ្តាល

**ក្រឡាបញ្ជីសវនាការ**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខៈ ១៩៨៩ អ.ក ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ÷

១- ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរជាងភ្លើង កម្រិតវប្បធម៌ថ្នាក់ទី៥ចាស់ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្នភូ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] ជុន (រស់) ម្តាយឈ្មោះ [redacted] អ៊ី (រស់) ប្រពន្ធឈ្មោះ [redacted] ស្រីវិន (រស់) គ្មានកូន ជាទីតិជន ទោសពីមុនគ្មាន។ **(ឃុំខ្លួនថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២១)**

-ជាប់ចោទពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រែកតាសោប ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោកស្រីមេធាវី [redacted] អាសយដ្ឋានផ្ទះលេខ ២២៤៥F ផ្លូវជាតិលេខ៥ ក្រុមទី១ ភូមិស្វាយប៉ាក សង្កាត់ស្វាយប៉ាក ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចិន។

២- ឈ្មោះ [redacted] ទីណា ហៅខ្មារ ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្នភូមិ[redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សារិទ្ធ (រស់) ម្តាយឈ្មោះ [redacted] ភើយ (រស់) នៅលីវ ជាអនីតិជន។ (គេចខ្លួន) ha

៣- ឈ្មោះ [redacted] សារុន ហៅខ្លួន ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើតនិងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] សារ៉ុន (រស់) ម្តាយឈ្មោះ [redacted] ស្តើង (រស់) នៅលីវ ជាអនីតិជន។ **(គេចខ្លួន)**

៤- ឈ្មោះ [redacted] ឡាង ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] លី (រស់) ម្តាយឈ្មោះ [redacted] ស្រីអួន (រស់) នៅលីវ ជានីតិជន។ **(គេចខ្លួន)**

៥- ឈ្មោះ [redacted] ដែន ភេទប្រុស អាយុ៣១ឆ្នាំ សញ្ជាតិខ្មែរ មុខរបរមិនពិតប្រាកដ ទីកន្លែងកំណើត និងទីលំនៅបច្ចុប្បន្នភូមិ [redacted] ខេត្តកណ្តាល ឪពុកឈ្មោះ [redacted] គឿន (រស់) ម្តាយឈ្មោះ [redacted] មឿន (រស់) នៅលីវ ជានីតិជន។ **(គេចខ្លួន)**

-ជាប់ចោទពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រែកតាសោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-លោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្លួន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន។

-ជនរងគ្រោះឈ្មោះ [redacted] គឹមស្រស់ ភេទស្រី អាយុ២៣ឆ្នាំ ទីលំនៅបច្ចុប្បន្នភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខៈ ៤០៤ ដកសព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាដំណោះស្រាយលេខៈ ៤២១ ដកដស ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២២ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកណ្តាល។

-បានឃើញ ដីកាចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះលេខៈ ៤៧៣ ដកចឲ/២២ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០២២ របស់ប្រធានសាលាដំបូងខេត្តកណ្តាល។

## <u>អង្គហេតុមានដូចតទៅ</u>

-កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង០៨ និង៣០នាទី មានករណី លួចមានស្ថានទម្ងន់ទោស (ឆក់កាបូប) ស្ថិតនៅភូមិព្រែកតាសោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ដែលបង្កឡើងដោយជនសង្ស័យឈ្មោះ [redacted] ចិន ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted] ទីណា ហៅខ្នារ ភេទប្រុស អាយុ១៧ឆ្នាំ។ ដោយមុនពេលកើតហេតុជនរងគ្រោះឈ្មោះ [redacted] គឹមស្រស់ ភេទស្រី អាយុ២៣ឆ្នាំ បានជិះម៉ូតូម៉ាក ZOOMER X ស៊េរីឆ្នាំ២០១៨ ជិះម្នាក់ឯងពីភ្នំពេញ ទៅស្រុកកំណើតនៅខេត្តកំពង់ធំ លុះជិះដល់កន្លែងកើតហេតុមានជនសង្ស័យចំនួន០២នាក់ ឈ្មោះ [redacted] ចិន និងឈ្មោះ [redacted] ទីណា ហៅខ្នារ បានជិះម៉ូតូម៉ាក HONDA C125 ស៊េរីឆ្នាំ២០១៥ ពណ៌ខ្មៅ គ្មានផ្លាកលេខ ឧបត្ថាជិះតាមជនរងគ្រោះពីក្រោយ ហើយបានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះបានសម្រេច រួចជិះសម្តៅទៅទិសខាងជើង ក្រោយមកជនរងគ្រោះបានជិះម៉ូតូដេញតាម លុះដល់ចំណុចភូមិព្រែកយាយហ៊ុនទី១ ជនសង្ស័យបម្រុងបត់ម៉ូតូត្រឡប់ក្រោយវិញតែត្រូវដួល ហើយជនសង្ស័យបានរត់ចូលព្រៃបាត់។ ក្រោយមកសមត្ថកិច្ចប៉ុស្តិ៍នគរបាលឬស្សីជ្រោយ ទទួលបានព័ត៌មាន ក៏បានស្រាវជ្រាវរកឃើញជនសង្ស័យឈ្មោះ [redacted] ចិន និងវត្ថុតាងហើយបាននាំមកកាន់អធិការដ្ឋាននគរបាលស្រុកមុខកំពូល ដើម្បីធ្វើការ



Scanned with CamScanner

សាកសួរ។ នៅមុខសមត្ថកិច្ចជនសង្ស័យឈ្មោះ [redacted] ចិន បានសារភាពថាកន្លងមកខ្លួន និងបក្សពួកឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្ទុន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន មានទីលំនៅភូមិឈើទាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ធ្លាប់ធ្វើសកម្មភាពឆក់កាបូប និងលួចម៉ូតូចំនួន ០៨លើករួចមកហើយ។ តាមកំណត់ហេតុធ្វើតេស្តទឹកនោមរបស់ឈ្មោះ [redacted] ចិន មានផ្ទុកនូវសារធាតុញៀន(+)។

**<u>ពេលសវនាការ</u>**

-ជនជាប់ចោទឈ្មោះ [redacted] ចិន បានឆ្លើយបញ្ជាក់ថា: សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១១ថ្ងៃត្រង់ បន្ទាប់ពីខ្លួនបានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះ ដែលជាស្ត្រីចំនួន០១នាក់ ហើយខ្លួនបានរត់ចូលទៅក្នុងព្រៃ។ នៅថ្ងៃកើតហេតុ វេលាម៉ោង០៨ព្រឹក ខ្លួន និងឈ្មោះ [redacted] ទីណា ហៅខ្នារ បានជិះម៉ូតូ០១គ្រឿងម៉ាក HONDA DREAM C125 សេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ដែលម៉ូតូនេះជាកម្មសិទ្ធិរបស់ម្តាយខ្លួន ដើម្បីធ្វើសកម្មភាពឆក់កាបូបពីស្ត្រីដែលជាជនរងគ្រោះ ជិះម៉ូតូម៉ាក ZOMMER X សេរីឆ្នាំ២០១៨ ពណ៌ក្រហម ក្នុងទិសដៅពីភ្នំពេញ ទៅកំពង់ធំ បានសម្រេចដោយឈ្មោះ [redacted] ទីណា ហៅខ្នារ ជាអ្នកឌុប ហើយខ្លួនជិះពីក្រោយ ជាអ្នកធ្វើសកម្មភាព។ ពេលឆក់កាបូបបានសម្រេចហើយ ពួកខ្លួនបានជិះម៉ូតូរត់គេចខ្លួន តែត្រូវស្ត្រីដែលជាជនរងគ្រោះ ជិះម៉ូតូដេញតាមពីក្រោយម៉ូតូពួកខ្លួន រហូតមកដល់ចំណុចភូមិព្រែកឃាយហ៊ុនទី១ ពួកខ្លួនរកបត់ម៉ូតូត្រឡប់ក្រោយវិញ តែត្រូវដួលម៉ូតូ។ ពួកខ្លួនបាននាំគ្នារត់ចូលទៅក្នុងព្រៃបាត់ ដោយខ្លួនជាអ្នកកាន់កាបូបជនរងគ្រោះជាប់នឹងដៃ ប៉ុន្តែខ្លួនពុំបានដឹងឈ្មោះ [redacted] ទីណា ហៅខ្នារ រត់ទៅឯណានោះទេ។ លុះដល់វេលាម៉ោង១១ព្រឹក ខ្លួនក៏បានដើរចេញពីក្នុងព្រៃមកវិញ ក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។ ខ្លួនធ្លាប់ធ្វើសកម្មភាព ជាមួយបក្សពួកខ្លួន មានឈ្មោះ ខ្នារ, ឈ្មោះ ដែន និងឈ្មោះ ឡាង បានសម្រេច ០៣ដង។ ពេលខ្លួនធ្វើសកម្មភាពលួចបាន ពួកខ្លួនយកប្រាក់មកចែកគ្នាស្មើ ដោយយកទៅចាយវាយខ្លះ និងទិញថ្នាំញៀនជក់ខ្លះ ដោយខ្លួនចេះជក់ថ្នាំញៀនរយៈពេល០១ឆ្នាំមកហើយ។ ចំពោះរឿងលួចម៉ូតូខ្លួនពុំបានប្រព្រឹត្តនោះទេ តែខ្លួនធ្លាប់ឮបក្សពួកខ្លួន វានិយាយថាពួកវាធ្លាប់លួចម៉ូតូគេចំនួន០៦ដងមកហើយ ដោយពេលលក់បាន ពួកវាបានយកលុយឱ្យខ្លួនចំនួន ១០ ដុល្លារអាមេរិច ទៅ ២០ ដុល្លារអាមេរិច ទុកសម្រាប់ចាយ។

-ជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ។ (គេចខ្លួន)

-ជនជាប់ចោទឈ្មោះ [redacted] សារុន ហៅខ្ទុន។ (គេចខ្លួន)

-ជនជាប់ចោទឈ្មោះ [redacted] ឡាង។ (គេចខ្លួន)

-ជនជាប់ចោទឈ្មោះ [redacted] ដែន។ (គេចខ្លួន)

-អំណានចម្លើយជនរងគ្រោះឈ្មោះ [redacted] គឹមស្រស់ បានឆ្លើយបញ្ជាក់ថា: នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង០៦ និង០០នាទី ខ្លួនបានចេញពីផ្ទះជួលនៅភូមិត្រពាំងពោធិ៍ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដោយជិះម៉ូតូម៉ាក ZOOMER X សេរីឆ្នាំ២០១៨ ដោយជិះតែម្នាក់ឯង ក្នុងគោលបំណងទៅលេងកូនស្រីខ្លួននៅភូមិត្រពាំងច្រនៀង ឃុំជ្រលង ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ លុះមកដល់ចំណុចឃុំឫស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ខ្លួនបានជិះម៉ូតូតិចៗ ដើម្បីរកកន្លែងចាក់សាំង ប្រហែលម៉ោង០៨ និង៣០នាទី ស្រាប់តែមានម៉ូតូ០១គ្រឿងម៉ាក HONDA DREAM C125 សេរីឆ្នាំ២០១៥ ជិះគ្នាពីរនាក់ ស្របទិសជាមួយខ្លួន ហើយបានធ្វើការឆក់យកកាបូបយួរដៃរបស់ខ្លួន ដែលស្ពាយនៅពីក្រោយខ្នងរបស់ខ្លួន ធ្វើឱ្យដាច់ខ្សែរស្ពាយ ហើយជនល្មើសទាំងពីរបានជិះម៉ូតូយ៉ាងលឿនទៅមុខបាត់។ ពេលនោះខ្លួន បានស្រែកឱ្យគេជួយ ហើយមានពូម្នាក់ដែលជាអ្នកដំណើរដូចគ្នាបានជិះដេញតាមពីក្រោយ ជនល្មើសនោះ ប្រហែលជា៦០ម៉ែត្រ ទើបម៉ូតូជនល្មើស

ដួលទៅលើថ្នល់ ហើយនាំគ្នារត់ចូលចំការចេកបាត់ ដោយមានលោកពូម្នាក់មិនស្គាល់ឈ្មោះ គាត់នៅអង្គុយចាំមើលដែលជនល្មើសរត់ចូលនោះ។ នៅម៉ោងប្រហែល០៨ និង៤០នាទី ទើបមានសមត្ថកិច្ចប៉ុស្តិ៍ឬស្សីជ្រោយបានមកដល់ ហើយបានចាប់យកជនល្មើសដែលត្រូវលោកពូម្នាក់មិនស្គាល់ឈ្មោះ ចាប់បាន យកមកប៉ុស្តិ៍នគរបាលរដ្ឋបាលឬស្សីជ្រោយតែម្តង។

-ក្រឡាបញ្ជីអានឯកសារនានានៅក្នុងសំណុំរឿងនេះ។

**<u>សិទ្ធិនិយាយស្តីរបស់ភាគីបន្ទាប់ពីចប់កិច្ចពិភាក្សាដេញដោល</u>**

-តំណាងអយ្យការបានសន្និដ្ឋានថា: សូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ: ៤០៤ ដកសព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ទុកជាការបានដដែល និងសុំឱ្យតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចិន បានសន្និដ្ឋានថា: កូនក្តីខ្ញុំបានឆ្លើយសារភាពនាពេលសវនាការ ចម្លើយកូនក្តីខ្ញុំនៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌គ្រាន់តែជាព័ត៌មាន។ សកម្មភាពនៃការប្រព្រឹត្តបទល្មើសមិនធ្ងន់ធ្ងរនោះទេ កូនក្តីខ្ញុំមានចេតនាគ្រាន់តែយកទ្រព្យសម្បត្តិតែប៉ុណ្ណោះ មិនមានការគាស់ទម្លុះទម្លាយនោះទេ។ ដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះកែប្រែបទចោទពីបទ: **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** តាមបញ្ញត្តិមាត្រា **៣៥៧** មកបទ: អំពើលួច តាមបញ្ញត្តិមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្ទន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន បានសន្និដ្ឋានថា: ដោយសារកូនក្តីខ្ញុំអវត្តមានគ្រប់ដំណាក់កាលនៃនីតិវិធីគ្មានចម្លើយនៅក្នុងសំណុំរឿង។ កូនក្តីខ្ញុំអត់បានប្រព្រឹត្តបទល្មើសនោះទេ ជនជាប់ចោទឈ្មោះ [redacted] ចិន គ្រាន់តែឆ្លើយដាក់តែប៉ុណ្ណោះ។ ដូច្នេះក្នុងនាមខ្ញុំជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចពិចារណាឱ្យកូនក្តីខ្ញុំរួចផុតពីបទចោទបទ: អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា។

**<u>ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាដេញដោល</u>**

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ចិន។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] គឹមស្រស់។

-ក្រោយពីបានស្តាប់ការអានឯកសារនានា។

-ក្រោយពីបានពិនិត្យភស្តុតាងនានានៅក្នុងសំណុំរឿង។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ចិន។

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្ទន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន។

-ក្រោយពីបានពិនិត្យពិចារណា និងពិភាក្សាក្រុមប្រឹក្សាត្រឹមត្រូវតាមច្បាប់។

**<u>សំអាងហេតុ</u>**

**<u>តុលាការយល់ឃើញថា</u>**

១- កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង០៨ និង៣០នាទី មានករណី អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ចិន និងករណី អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ដែលបង្កឡើងដោយជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្ទន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន ដែលប្រព្រឹត្តនៅភូមិព្រែកតាសោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល ពិតប្រាកដមែន។



Scanned with CamScanner

35/5

២- ពេលសវនាការជនជាប់ចោទឈ្មោះ [redacted] ចិន បានឆ្លើយបញ្ជាក់ថាៈ សមត្ថកិច្ចឃាត់ខ្លួននៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង១១ថ្ងៃត្រង់ បន្ទាប់ពីខ្លួនបានធ្វើសកម្មភាពឆក់កាបូបរបស់ជនរងគ្រោះ ដែលជាស្ត្រីចំនួន០១នាក់ ហើយខ្លួនបានរត់ចូលទៅក្នុងព្រៃ។ នៅថ្ងៃកើតហេតុ វេលាម៉ោង០៨ព្រឹក ខ្លួន និងឈ្មោះ [redacted] ទីណា ហៅខ្នារ បានជិះម៉ូតូ០១គ្រឿងម៉ាក HONDA DREAM C125 សេរីឆ្នាំ២០១៥ ពណ៌ខ្មៅ មិនចាំផ្លាកលេខ ដែលម៉ូតូនេះជាកម្មសិទ្ធិរបស់ម្តាយខ្លួន ដើម្បីធ្វើសកម្មភាពឆក់កាបូបពីស្ត្រីដែលជាជនរងគ្រោះ ជិះម៉ូតូម៉ាក ZOMMFR X សេរីឆ្នាំ២០១៨ ពណ៌ក្រហម ក្នុងទិសដៅពីភ្នំពេញ ទៅកំពង់ធំ បានសម្រេចដោយឈ្មោះ [redacted] ទីណា ហៅខ្នារ ជាអ្នកឌុប ហើយខ្លួនជិះពីក្រោយ ជាអ្នកធ្វើសកម្មភាព។ ពេលឆក់កាបូបបានសម្រេចហើយ ពួកខ្លួនបានជិះម៉ូតូរត់គេចខ្លួន តែត្រូវស្ត្រីដែលជាជនរងគ្រោះ ជិះម៉ូតូដេញតាមពីក្រោយម៉ូតូពួកខ្លួន រហូតមកដល់ចំណុចភូមិព្រៃកយាយហ៊ិនទី១ ពួកខ្លួនរកបត់ម៉ូតូត្រឡប់ក្រោយវិញ តែត្រូវដួលម៉ូតូ។ ពួកខ្លួនបាននាំគ្នារត់ចូលទៅក្នុងព្រៃបាត់ ដោយខ្លួនជាអ្នកកាន់កាបូបជនរងគ្រោះជាប់នឹងដៃ ប៉ុន្តែខ្លួនពុំបានដឹងឈ្មោះ [redacted] ទីណា ហៅខ្នារ រត់ទៅឯណានោះទេ។ លុះដល់វេលាម៉ោង១១ព្រឹក ខ្លួនក៏បានដើរចេញពីក្នុងព្រៃមកវិញ ក៏ត្រូវសមត្ថកិច្ចធ្វើការឃាត់ខ្លួនតែម្តង។ ខ្លួនធ្លាប់ធ្វើសកម្មភាព ជាមួយបក្សពួកខ្លួន មានឈ្មោះ ខ្នារ, ឈ្មោះ ដែន និងឈ្មោះ ឡាង បានសម្រេច០៣ដង។ ពេលខ្លួនធ្វើសកម្មភាពលួចបាន ពួកខ្លួនយកប្រាក់មកចែកគ្នាស្មើ ដោយយកទៅចាយវាយខ្លះ និងទិញថ្នាំញៀនជក់ខ្លះ ដោយខ្លួនចេះជក់ថ្នាំញៀនរយៈពេល០១ឆ្នាំមកហើយ។ ចំពោះរឿងលួចម៉ូតូខ្លួនពុំបានប្រព្រឹត្តនោះទេ តែខ្លួនធ្លាប់ឮបក្សពួកខ្លួន វានិយាយថាពួកវាធ្លាប់លួចម៉ូតូគេចំនួន០៦ដងមកហើយ ដោយពេលលក់បានពួកវាបានយកលុយឱ្យខ្លួនចំនួន ១០ ដុល្លារអាមេរិច ទៅ ២០ ដុល្លារអាមេរិច ទុកសម្រាប់ចាយ។ ចម្លើយសារភាពនេះមានលក្ខណៈស៊ីចង្វាក់គ្នាទៅនឹងចម្លើយរបស់ជនជាប់ចោទនៅគ្រប់ដំណាក់កាលនីតិវិធី ស៊ីចង្វាក់គ្នាទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ីចង្វាក់ទៅនឹងឯកសារគតិយុត្តនានាដែលកសាងឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ បញ្ជាក់បានថាឈ្មោះ [redacted] ចិន ពិតជាបានធ្វើសកម្មភាពឆក់កាបូប របស់ជនរងគ្រោះឈ្មោះ ហ៊ិល គីមស្រស់ ប្រាកដមែន។

៣- ជនជាប់ចោទឈ្មោះ [redacted] ចិន បានឆ្លើយសារភាពថាៈ ខ្លួនចេះប្រើប្រាស់ថ្នាំញៀនរយៈពេល០១ឆ្នាំមកហើយ។ នៅថ្ងៃកើតហេតុ មុនពេលសមត្ថកិច្ចចាប់ខ្លួន ខ្លួនបានប្រើប្រាស់ថ្នាំញៀនផងដែរ។ ចម្លើយសារភាពនេះមានលក្ខណៈស៊ីចង្វាក់ទៅនឹងកំណត់ហេតុ ធ្វើតេស្តទឹកនោម ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកមុខកំពូល ដែលបានធ្វើតេស្តលើជនជាប់ចោទឈ្មោះ [redacted] ចិន ជាលទ្ធផលដែលបានមកពីការប្រតិកម្មរបស់ឧបករណ៍ពិសោធន៍ទឹកនោម បង្ហាញជាលទ្ធផល÷ វិជ្ជមាន (+)។

៤- ជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្ពុន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន បានរត់គេចខ្លួន ពុំមានចម្លើយក្នុងសំណុំរឿង ប៉ុន្តែបើផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ ជុន ចិន បញ្ជាក់ថាៈ ជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្ពុន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន ជាបក្សពួកខ្លួនធ្លាប់បានធ្វើសកម្មភាពឆក់ទ្រព្យសម្បត្តិគេជាមួយគ្នានាពេលកន្លងមក។ ដូច្នេះ បញ្ជាក់បានថា ពេលធ្វើសកម្មភាពឆក់កាបូបជនរងគ្រោះឈ្មោះ [redacted] គីមស្រស់ ជាស្ត្រីម្នាក់បានសម្រេចកាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ ក៏មានវត្តមានអ្នកទាំងអស់នេះចូលរួមផងដែរ គ្រាន់តែជនជាប់ចោទឈ្មោះ [redacted] ចិន ឆ្លើយលាក់លៀម បិទបាំង នូវអំពើប្រព្រឹត្តរបស់បក្សពួកខ្លួន តែប៉ុណ្ណោះ។ na



Scanned with CamScanner

៥- តាមរបាយការណ៍សរុបលេខៈ ៦៣៥ របក ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកមុខកំពូល បញ្ជាក់បានថា÷ កន្លងមកឈ្មោះ [redacted] ចិន និងបក្សពួកឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted]សារុន ហៅខ្លួន, ឈ្មោះ [redacted]ឡាង និងឈ្មោះ [redacted] ដែន ធ្លាប់ធ្វើសកម្មភាពឆក់កាបូប និងលួចម៉ូតូ ចំនួន០៨លើករួចមកហើយ លុះដល់ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង០៨ និង៣០នាទី ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted]ទីណា ហៅខ្នារ ភេទប្រុស អាយុ១៧ឆ្នាំ មានទីលំនៅបច្ចុប្បន្នភូមិឈើទាល ឃុំព្រែកអញ្ចាញ ស្រុកមុខកំពូល ខេត្តកណ្តាល ពិតជាបានធ្វើសកម្មភាពឆក់កាបូប របស់ជនរងគ្រោះឈ្មោះ [redacted]គីមស្រស់ នៅភូមិព្រែកតាសោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ពិតប្រាកដមែន។

៦- តាមកំណត់ចាប់យកវត្ថុតាង ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់អធិការដ្ឋាននគរបាលស្រុកមុខកំពូល រួមមាន÷

ក. ម៉ូតូចំនួន០១គ្រឿងម៉ាក HONDA C125 ពណ៌ខ្មៅ សេរីឆ្នាំ២០១៥ គ្មានផ្លាកលេខ ជាមធ្យោបាយដែលជនជាប់ចោទប្រព្រឹត្តបទល្មើស។

ខ. លុយដុល្លារចំនួន ១១០$ (មួយរយដប់ដុល្លារអាមេរិច), លុយខ្មែរចំនួន ១៣៥,៥០០ (ដប់បីម៉ឺនប្រាំពាន់ប្រាំរយរៀល), កាបូបដៃចំនួន០១ពណ៌ត្នោត, ទូរស័ព្ទចំនួន០១គ្រឿងម៉ាក IPHONE 7 ពណ៌ទឹកមាស, អត្តសញ្ញាណប័ណ្ណខ្មែរចំនួន០១ និងកាតចាក់វ៉ាក់សាំងកូវីត១៩ ចំនួន០១ ដែលជារបស់ជនរងគ្រោះ។

៧- អំពើប្រព្រឹត្តរបស់ជនជាប់ចោទ÷

ក. ឈ្មោះ [redacted] ចិន មានចេតនាទុច្ចរិតដកហូតទ្រព្យសម្បត្តិអ្នកដ៏ទៃក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយបានធ្វើការឆក់កាបូបពីជនរងគ្រោះ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន គឺជាបទល្មើសព្រហ្មទណ្ឌបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. ឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្លួន, ឈ្មោះ [redacted]ឡាង និងឈ្មោះ [redacted] ដែន មានចេតនាទុច្ចរិតដកហូតទ្រព្យសម្បត្តិអ្នកដ៏ទៃក្នុងគោលបំណងយកមកធ្វើជាកម្មសិទ្ធិរបស់ខ្លួន ដោយបានធ្វើសកម្មភាពឆក់ជាច្រើនលើក គឺជាបទល្មើសព្រហ្មទណ្ឌបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ។

៨- តំណាងអយ្យការបានប្តឹងសុំឱ្យតុលាការតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខៈ ៤០៤ ដកសព ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២២ ទុកជាការបានដដែល និងសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ឃើញថាមានលក្ខណៈត្រឹមត្រូវតាមច្បាប់ តុលាការនឹងពិចារណាចំពោះការប្តឹងសុំនេះ។

៩- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]ចិន បានធ្វើសេចក្តីសន្និដ្ឋានថាៈ កូនក្តីខ្លួនបានឆ្លើយសារភាពនាពេលសវនាការ ចម្លើយកូនក្តីខ្លួននៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌គ្រាន់តែជាព័ត៌មាន។ សកម្មភាពនៃការប្រព្រឹត្តបទល្មើសមិនធ្ងន់ធ្ងរនោះទេ កូនក្តីខ្លួនមានចេតនាគ្រាន់តែយកទ្រព្យសម្បត្តិតែប៉ុណ្ណោះ មិនមានការតាស៊ូទម្លុះទម្លាយនោះទេ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះកែប្រែបទចោទពីបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា តាមបញ្ញត្តិមាត្រា ៣៥៧ ៗ



Scanned with CamScanner

35/3

មកបទៈ អំពើលួច តាមបញ្ញត្តិមាត្រា **៣៥៦** នៃក្រមព្រហ្មទណ្ឌ។ តុលាការពិចារណាឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ដែលអាចឱ្យតុលាការសម្រេចតាមការស្នើសុំបាននោះទេ ជនជាប់ចោទពុំបានគាស់ទម្លុះទម្លាយមែន ប៉ុន្តែជនជាប់ចោទ បានធ្វើសកម្មភាពឆក់កាបូបជនរងគ្រោះបានសម្រេច ដែលអំពើនេះជាការប្រើហិង្សាទៅលើរាងកាយជនរងគ្រោះ ដើម្បីយកទ្រព្យសម្បត្តិ ដូចមានចែងក្នុងមាត្រា **៣៥៧ ចំណុចទី១** នៃក្រមព្រហ្មទណ្ឌ ហើយជនជាប់ចោទក៏ធ្លាប់ធ្វើសកម្មភាពឆក់ និងលួចម៉ូតូ ជាច្រើនលើកផងដែរ។

១០- មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្មារ និងឈ្មោះ [redacted] សារុន ហៅខ្លុន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន បានធ្វើសេចក្តីសន្និដ្ឋានថាៈ ដោយសារកូនក្តីខ្លួនអវត្តមានគ្រប់ដំណាក់កាលនៃនីតិវិធី គ្មានចម្លើយនៅក្នុងសំណុំរឿង។ កូនក្តីខ្លួនអត់បានប្រព្រឹត្តបទល្មើសនោះទេ ជនជាប់ចោទឈ្មោះ [redacted] ចិន គ្រាន់តែឆ្លើយដាក់តែប៉ុណ្ណោះ។ ដូច្នេះក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះ ពិចារណាសម្រេចឱ្យកូនក្តីខ្លួនរួចផុតពីបទចោទបទៈ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា**។ តុលាការពិចារណាឃើញថា ពុំមានភស្តុតាងគ្រប់គ្រាន់ដែលអាចឱ្យតុលាការសម្រេចតាមការស្នើសុំបាននោះទេ ព្រោះបើផ្អែកតាមចម្លើយសារភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ចិន វត្ថុតាងនានា និងរបាយការណ៍សរុបរបស់មន្ត្រីនគរបាលយុត្តិធម៌ ស្រុកមុខកំពូល បញ្ជាក់ថា ជនជាប់ចោទទាំងអស់ជាបក្សពួកតែមួយ ជាមួយជនជាប់ចោទឈ្មោះ [redacted] ចិន និងធ្លាប់ធ្វើសកម្មភាពឆក់ និងលួចម៉ូតូ ជាច្រើនលើកមកហើយ។

១១- ជនជាប់ចោទឈ្មោះ [redacted] ចិន, ឈ្មោះ [redacted] ឡាង, ឈ្មោះ [redacted] ដែន ជានីតិជន និងជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្មារ, ឈ្មោះ [redacted] សារុន ហៅខ្លុន ជាអនីតិជន មានស្មារតីគ្រប់គ្រាន់ សមត្ថភាពគ្រប់គ្រាន់ អាចទទួលខុសត្រូវនូវអំពើដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ពុំមានភស្តុតាងណាមួយ ដែលបញ្ជាក់ថាជនជាប់ចោទមានវិប្លាសស្មារតីនោះទេ ដូច្នេះជនជាប់ចោទមានសមត្ថភាពទទួលខុសត្រូវខាងព្រហ្មទណ្ឌ។

១២- ក្រោយពីបានពិនិត្យ ពិចារណាលើភស្តុតាង និងរាល់សេចក្តីសន្និដ្ឋានរបស់ភាគី តុលាការប្រកាសថាៈ មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទ÷

ក. ឈ្មោះ [redacted] ចិន ពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិព្រៃកតាសោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា **៣៥៧ ចំណុចទី១** នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. ឈ្មោះ [redacted] ទីណា ហៅខ្មារ, ឈ្មោះ [redacted] សារុន ហៅខ្លុន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន ពីបទៈ **អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅភូមិព្រៃកតាសោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា **៣៥៧ ចំណុចទី១ មាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ ចំណុចទី៣** នៃក្រមព្រហ្មទណ្ឌ។



Scanned with CamScanner

35/2

១៣- អំពើប្រព្រឹត្តរបស់ជនជាប់ចោទឈ្មោះ [redacted] ចិន, ឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្ពុន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន បានធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិអ្នកដទៃ សណ្តាប់ធ្នាប់សាធារណៈ របៀបរៀបរយសង្គម និងច្បាប់របស់រដ្ឋ។

១៤- ជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ និងឈ្មោះ [redacted] សារុន ហៅខ្ពុន ជាអនីតិជន។ ដូច្នេះគប្បីតុលាការសម្រេចផ្តន្ទាទោស ដោយអនុវត្តតាមមាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ។

១៥- វត្ថុតាង÷ ម៉ូតូ០១គ្រឿងម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ គ្មានផ្លាកលេខ (មិនប្រក្រតី) ដែលជាមធ្យោបាយប្រព្រឹត្តបទល្មើស គប្បីតុលាការសម្រេចរឹបអូស តាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

១៦- ជនរងគ្រោះឈ្មោះ [redacted] គឹមស្រស់ មិនបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងមិនទាមទារសំណងខូចខាត នឹងជម្ងឺចិត្តនោះទេ។ ដូច្នេះគប្បីតុលាការមិនពិចារណាលើបញ្ហានេះឡើយ។

១៧- ក្រោយពេលប្រព្រឹត្តបទល្មើស ជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្ពុន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន បានរត់គេចខ្លួនបាត់។ ដូច្នេះគប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់ខ្លួន តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## <u>សេចក្តីសម្រេច</u>

១- ផ្តន្ទាទោស÷

ក. ឈ្មោះ [redacted] ចិន ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤ (បួន)ឆ្នាំ។

ពីបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិព្រៃកតាសោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣, មាត្រា ៣៥៧ ចំណុចទី១ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ខ. ឈ្មោះ [redacted] ទីណា ហៅខ្នារ ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ)ឆ្នាំ។

គ. ឈ្មោះ [redacted] សារុន ហៅខ្ពុន ភេទប្រុស អាយុ១៧ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០២ (ពីរ)ឆ្នាំ។

ឃ. ឈ្មោះ [redacted] ឡាង ភេទប្រុស អាយុ១៨ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤ (បួន)ឆ្នាំ។

ង. ឈ្មោះ [redacted] ដែន ភេទប្រុស អាយុ៣១ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់ ០៤ (បួន)ឆ្នាំ។

ពីបទៈ អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅភូមិព្រៃកតាសោម ឃុំឬស្សីជ្រោយ ស្រុកមុខកំពូល ខេត្តកណ្តាល កាលពីថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ ចំណុចទី១ មាត្រា ១៦០ កថាខណ្ឌទី១ ចំណុចទី១ ចំណុចទី៣ នៃក្រមព្រហ្មទណ្ឌ។

២- វត្ថុតាង÷ ម៉ូតូ០១គ្រឿងម៉ាក HONDA DREAM C125 ពណ៌ខ្មៅ ស៊េរីឆ្នាំ២០១៥ គ្មានផ្លាកលេខ (មិនប្រក្រតី) សម្រេចរឹបអូសតាមមាត្រា ៦២ នៃក្រមព្រហ្មទណ្ឌ។

៣- បង្គាប់ឱ្យចាប់ខ្លួនឈ្មោះ [redacted] ទីណា ហៅខ្នារ ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] សារុន ហៅខ្ពុន ភេទប្រុស អាយុ១៧ឆ្នាំ, ឈ្មោះ [redacted] ឡាង ភេទប្រុស អាយុ១៨ឆ្នាំ និងឈ្មោះ [redacted] ដែន ភេទប្រុស អាយុ៣១ឆ្នាំ តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។



Scanned with CamScanner

-សាលក្រមនេះជំនុំជម្រះជាអសាធារណៈនៅថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចិន និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ទីណា ហៅខ្នារ, ឈ្មោះ [redacted] សារុន ហៅខ្វន, ឈ្មោះ [redacted] ឡាង និងឈ្មោះ [redacted] ដែន និងប្រកាសជាអសាធារណៈនៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២។ ទុកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|---|
| ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: | ហត្ថលេខា និងត្រា: |

[redacted]

---

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃពុធ ១រោច ខែជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦
កណ្តាល, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២
**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ
កណ្តាល, ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០២២
**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]